# រឿង សម្លាញ់បីនាក់



ឆ្នាំ ២០១០


អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន

អ្នករៀបរៀង : លោកស្រី ឈុំ សារ៉ានី

វិចិត្រករ : លោក អ៊ុត រឿន



បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អរ.សសរ.

ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល

រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

អំណោយ អ៊ុយនីសេហ្វ

DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រែសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10016

រោងពុម្ព : J S R C Printing House

សម្លាញ់បីនាក់ឈ្មោះ៖ ម៉ាប់ជាកូនជ្រូក ពាលជាកូនឆ្កែ ចែជាកូនមាន់ រស់នៅយ៉ាងសុខសាន្តក្នុងទីធ្លាចិញ្ចឹមសត្វមួយ។

ថ្ងៃមួយម៉ាប់និយាយទៅកាន់ពាលថា៖

- បងពាលឯងចង់ធាត់ធំមានសុខភាពល្អដូចខ្ញុំដែរឬទេ?

ពាលឆ្លើយ៖

- បាទ ចង់ណាស់ម៉ាប់...តែខ្ញុំមិនដឹងធ្វើដូចម្ដេច?
- ឱស្រួលណាស់ពាលអើយ គឺពាលឯងត្រូវដេកហូប ហូបឱ្យបានច្រើនជាទីបំផុត។ ឯងដឹងទេថាគ្មានអ្វីធំជាងដំណេក និង ការហូបទេដែលធ្វើឱ្យឯងមានសុខភាពល្អ។





ពោលចប់សម្ដីនេះភ្លាម   ម៉ាប់កន្ទាត់ក៏ដេកលង់លក់ទៅ។ ឯពាលកូនឆ្កែវិលមកកន្លែងដើមវិញ។





គាប់ជួនពេលនោះ ចៃកូនមាន់ដើរយ៉ាងសង្ហាមកជិតពាល ដែលកំពុងតែដេកស្ដូកស្ដឹង ប្លែកពីធម្មតាក៏ទទះស្លាបរងាវមួយបទ យ៉ាងពីរោះរូចសួរថាៈ

- នែសម្លាញ់ ឯងឈឺឬ?

- ពាលឆ្លើយៈ ទេខ្ញុំឥតឈឺទេ ខ្ញុំធ្វើតាមបងម៉ាប់ប្រាប់ទេតើ ព្រោះបងម៉ាប់ថាៈ

បើខ្ញុំធ្វើដូចគាត់បាន ខ្ញុំច្បាស់ជាធំធាត់ ដូចគាត់មិនខាន។





- ហាស ហាស ចែសើចរួចពោលថា៖

- នែពាលអើយ ម៉ាប់ជាកូនជ្រូកកន្ទ្រាត់កម្ជិលផេះទេតើ ។ ការធំធាត់ និងសុខភាពល្អគឺស្ថិតនៅលើការហាត់ប្រាណ ការសំអាតខ្លួន និងការប្រកាន់ខ្ជាប់នូវពេលគេង ពេលហូបឱ្យបានទៀងទាត់។







ចាប់ពីពេលនោះមក ពាលកូនឆ្កែក៏ធ្វើតាមចៃកូនមាន់ ហើយទទួលបានសុខភាពល្អបរិបូណ៌ និង មានកម្លាំងមាំមួនមិនដូចម៉ាប់កូនជ្រូក ដែលគ្រាន់តែធាត់ហើយគ្មានកម្លាំងកាយនោះទេ។



ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

This aid project is supported by all participants in Japan's Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317033